**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Feb-2015, 15:39
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈជាមួយឧបសម្ពន្ធសម្ងាត់បំផុត៤

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ការដាក់បញ្ជាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារនានាពីសំណុំរឿង004 ដែលពាក់ព័ន្ធនឹងសំណុំរឿង00២ អនុលោមតាមសំណុំរឿង004-D193/11**

---

**<u>អ្នកដាក់ឯកសារ:</u>**
**សហព្រះរាជអាជ្ញា**
លោក Nicholas KOUMJIAN

**<u>ចម្លងជូន:</u>**
លោកស្រី ជា លាង

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

**<u>អ្នកទទួលឯកសារ:</u>**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**<u>ចម្លងជូន:</u>**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**
លោកស្រី ទូច វល័ក្ស
លោក Calvin SAUNDERS

# I. ការដាក់បង្ហាញ

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") សូមដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយចំនួនកៅសិប(៩០) ("ឯកសារ") ដែលបានទទួលយកនៅក្នុងសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង០០២/០២។ មានឯកសារមួយចំនួនផងដែរ ឋិតនៅក្នុងឯកសារចំនួនពីរ(០២)ប្រភេទ ("ប្រភេទឯកសាររបស់មេធាវីការពារក្តី") ដែលតាមទស្សនៈរបស់ពួកគាត់ មេធាវីការពារក្តី នួន ជា ធ្លាប់បានធ្វើការកំណត់អត្តសញ្ញាណថាមាន "សក្តានុពលដោះបន្ទុក" នៅក្នុងបរិបទនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១[1]។ រាល់ឯកសារទាំងអស់ ត្រូវបានកំណត់អត្តសញ្ញាណជាសម្ងាត់បំផុតនៅក្នុង **ឧបសម្ព័ន្ធ ជ** និង មានផ្តល់នូវការចង្អុលបង្ហាញចំពោះឯកសារទាំងឡាយណា ដែលមានលក្ខណៈឆ្លើយតបទៅនឹងប្រភេទឯកសាររបស់មេធាវីការពារក្តី។

2. សហព្រះរាជអាជ្ញាបានស្វែងរកការស្នើសុំដាក់បង្ហាញឯកសារនានា ដែលរួមបញ្ចូលនៅក្នុងការដាក់បង្ហាញនេះ តាមរយៈសំណើសុំចំនួនពីរ(០២) (ជារួម "សំណើសុំ") ដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ និងថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥[2]។ សចសអ បានអនុញ្ញាតលើសំណើសុំនេះជាផ្នែក នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលសេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធចំនួនពីរ(០២) ដែលសហព្រះរាជអាជ្ញាបានភ្ជាប់មក ជាមួយនេះ ថាជាឧបសម្ព័ន្ធសម្ងាត់បំផុត ១, ២ និង ៣[3]។

---

[1] **F2/4** សំណើលើកទីបី សុំឲ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខប្រឆាំងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១, ២៥ វិច្ឆិកា ២០១៤, កថាខណ្ឌ ៣៣។ ខណៈដែលសហព្រះរាជអាជ្ញាមិនយល់ស្របថាប្រភេទឯកសារនានាដែលបានកំណត់ដោយមេធាវីការពារក្តី នួន ជា មានភាពពាក់ព័ន្ធជាការដោះបន្ទុកចំពោះបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ នោះសហព្រះរាជអាជ្ញាបានស្នើសុំឲ្យ សចសអ ផ្តល់ការពិចារណាជាអាទិភាពលើការដាក់បង្ហាញឯកសារទាំងនេះជាប្រយោជន៍ដើម្បីឲ្យមេធាវីការពារក្តី នួន ជា មានឱកាសធ្វើការពិនិត្យឯកសារទាំងនោះឡើងវិញសម្រាប់បណ្តឹងសាទុក្ខរបស់ពួកគាត់។

[2] សំណុំរឿង ០០៤-**D193/7** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង០០២/០២ និងបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១, ១៥ ធ្នូ ២០១៤។ សំណុំរឿង០០៤-**D193/9** សំណើរបស់ សពអ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ ក្នុងសំណុំរឿង០០២/០២, ២៩ មករា ២០១៥។

[3] សំណុំរឿង០០៤-**D193/11** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ D193/7 និង D193/9 សម្រាប់សំណុំរឿង០០២, ៤ កុម្ភៈ ២០១៥។

3. អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា កាតព្វកិច្ចដើម្បីបង្ហាញឯកសារពាក់ព័ន្ធ ទោះជាដាក់បន្ទុក ឬដោះបន្ទុកក្តី គឺជាកាតព្វកិច្ចមួយដែលអង្គជំនុំជម្រះសាលាដំបូងមាន ក៏ដូចគ្នានឹងជនជាប់ចោទដែរ ដោយហេតុថា "ជាប្រយោជន៍ដែលនាំដល់ការស្វែងរកការពិត ដែលអង្គជំនុំជម្រះមានសិទ្ធិចូលពិនិត្យមើលឯកសារទាំងនេះ"[4]។ ជាងនេះទៀត អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនថា "វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចជាបន្តបន្ទាប់ទៅលើសហព្រះរាជអាជ្ញា ក្នុងការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវឯកសារណាមួយដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួនដែលអាចជានត្ថិភាពនៃពិរុទ្ធ ឬសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចមានឥទ្ធិពលទៅលើភាពជឿជាក់បាននៃភស្តុតាង"[5]។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំថា សហព្រះរាជអាជ្ញាដំបូងត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះឲ្យទទួលបានភស្តុតាង ដែលសហព្រះរាជអាជ្ញាចង់ដាក់បង្ហាញ និងបន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឲ្យទទួលយកឯកសារនោះដែលអនុម័តឲ្យមានការដាក់បង្ហាញឯកសារ[6]។

4. អង្គជំនុំជម្រះសាលាដំបូងពីមុនធ្លាប់បានបង្គាប់ថា គ្រប់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គម្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្តោះអាសន្នដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះថាតើ គម្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[7]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីកំណត់ហេតុដែលមាននៅក្នុង **ឧបសម្ព័ន្ធ ជ** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។

---

[4] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ២០១២។

[5] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ២០១២, ត្រង់ទំព័រទី១។

[6] **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងចម្លើយសាក្សីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

[7] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២, ត្រង់ទំព័រទី១។

5. ការអនុញ្ញាតដាក់បង្ហាញឯកសាររបស់ សចសអ គឺស្ថិតនៅក្រោមលក្ខខណ្ឌដូចបានគូសបង្ហាញក្នុងសេចក្តីសម្រេចពីមុនៗរបស់ សចសអ និងដូចមានចែងនៅក្នុងសេចក្តីជូនដំណឹងអំពីការដាក់បង្ហាញឯកសារមុនៗ[8]។ ដើម្បីអនុវត្តតាមការដាក់កម្រិតទាំងនេះ សហព្រះរាជអាជ្ញានឹងធ្វើយ៉ាងណាឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន និងមេធាវីប្រចាំការរបស់ ខៀវ សំផន នូវឯកសារដែលបានដាក់សញ្ញាសម្គាល់ និងលេខលើសំណៅចម្លងនៃឯកសារនិមួយៗ ដល់គ្រប់ភាគីទាំងអស់ ឲ្យបានឆាប់តាមដែលអាចធ្វើបាន។

## II. ដំណោះស្រាយដែលស្នើឡើង

6. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយក និងដាក់បញ្ចូលក្នុងសំណុំរឿង០០២ នូវកំណត់ហេតុស្តាប់ចម្លើយទាំងឡាយ ដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ ជ**៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |

[8] *សូមមើល ឧទាហរណ៍,* **E319.12.1.1** ដីកាសម្រេចផ្នែកខ្លះលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារស្តាប់ចម្លើយសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង០០២/០២ និងបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០២/០១ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៥, ២១ មករា ២០១៥, ត្រង់កថាខណ្ឌ១៤, ១៥, ១៧ និង១៨។